ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

**សាលាដំបូងខេត្តឧត្តរមានជ័យ**

សំណុំរឿងរដ្ឋប្បវេណីលេខ: ១១៣

ចុះថ្ងៃទី០៦ ខែតុលា ឆ្នាំ២០២៣

សាលក្រមលេខ៖ **៦០(ក)/៩៦**

ចុះថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០២៣

# តាងនាមប្រជារាស្ត្រខ្មែរ
# សាលាដំបូងខេត្តឧត្តរមានជ័យ

បានបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់ នៅថ្ងៃទី០៦ ខែវិច្ឆិកា ឆ្នាំ២០២៣

នៅសាលជម្រះក្តី នៃសាលាដំបូងខេត្តឧត្តរមានជ័យ ។

## ចៅក្រមជំនុំជម្រះ

ឯកឧត្តម [redacted] ជាប្រធាន និងជាចៅក្រម នៃសាលាដំបូងខេត្តឧត្តរមានជ័យ

## ក្រឡាបញ្ជីសវនាការ

លោក [redacted] ជាក្រឡាបញ្ជី នៃសាលាដំបូងខេត្តឧត្តរមានជ័យ

បានធ្វើការទាញហេតុផលដោយផ្ទាល់មាត់ជាសាធារណៈ លើសំណុំរឿងរដ្ឋប្បវេណីលេខ: ១១៣ ចុះថ្ងៃទី០៦ ខែតុលា ឆ្នាំ២០២៣ ដែលមានគូវិវាទរវាង៖

-ដើមចោទឈ្មោះ [redacted] គីមហៀក ភេទស្រី កើតឆ្នាំ១៩៨៩ សញ្ជាតិខ្មែរ បច្ចុប្បន្ននៅ [redacted] ដោយមានលោក [redacted] ជាមេធាវីតំណាងដោយអាណត្តិ ។

-ចុងចម្លើយឈ្មោះ [redacted] រ៉ាត ភេទប្រុស អាយុ៣៨ឆ្នាំ សញ្ជាតិខ្មែរ បច្ចុប្បន្នកំពុងជាប់ឃុំខ្លួន នៅពន្ធនាគារខេត្ត [redacted] ។

## ១.អង្គហេតុ និងការអះអាងរបស់គូភាគី៖

១.១/ ខ្លឹមសារសាលក្រមដែលដើមចោទទាមទារ៖

១.១.១/ ប្តឹងសុំលែងលះពីចុងចម្លើយឈ្មោះ [redacted] រ៉ាត ចាប់ពីពេលនេះតទៅ ។

១.១.២/ ប្តឹងសុំសិទ្ធិគ្រប់គ្រងកូនចំនួន០៣នាក់ ១.ឈ្មោះ [redacted] សុខណៃ ភេទស្រី កើតថ្ងៃទី៣០ ខែមករា ឆ្នាំ២០១០, ២.ឈ្មោះ [redacted] សុខណា ភេទស្រី កើតថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០១៣ និង ៣.ឈ្មោះ [redacted] មន្នីរាជ ភេទប្រុស កើតថ្ងៃទី០៤ ខែកញ្ញា ឆ្នាំ២០២០ មកឲ្យដើមចោទជាអ្នកទទួលបន្ទុកគ្រប់គ្រង និងចិញ្ចឹមបីបាច់រក្សារហូតដល់នីតិភាព ។

១.១.៣/ ប្តឹងសុំបែងចែកទ្រព្យសម្បត្តិរួម មានដីចំនួន០១កន្លែង មានទំហំ៣២ម៉ែត្រ គុណនឹង ១២០ម៉ែត្រ និងផ្ទះឈើទំហំ១០ម៉ែត្រ គុណនឹង២០ម៉ែត្រ ទីតាំងស្ថិតនៅភូមិត្រាំចាន ឃុំព្រះប្រឡាយ ស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ ប្រគល់ឲ្យកូនបង្កើតចំនួន០៣នាក់ ជាចំណែកដូចតទៅ៖



Scanned with CamScanner

-កូនទី១ ឈ្មោះ [redacted]សុខណៃ ភេទស្រី កើតថ្ងៃទី៣០ ខែមករា ឆ្នាំ២០១០ (អនីតិជន) ទទួលបាន ចំណែក ១ភាគ៣ នៃ ដី និងផ្ទះខាងលើ។ (ឲ្យដើមចោទជាអ្នកតំណាងទទួលដី និងផ្ទះជំនួសកូនរហូតដល់នីតិភាព)

-កូនទី២ ឈ្មោះ [redacted]សុខណា ភេទស្រី កើតថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០១៣ (អនីតិជន) ទទួលបាន ចំណែក១ភាគ៣ នៃដី និងផ្ទះខាងលើ ។ (ឲ្យដើមចោទជាអ្នកតំណាងទទួលដី និងផ្ទះជំនួសកូនរហូតដល់នីតិភាព)

-កូនទី៣ ឈ្មោះ [redacted] មន្នីរាជ ភេទប្រុស កើតថ្ងៃទី០៤ ខែកញ្ញា ឆ្នាំ២០២០ (អនីតិជន) ទទួល បានចំណែក១ភាគ៣ នៃ ដី និងផ្ទះខាងលើ ។ (ឲ្យដើមចោទជាអ្នកតំណាងទទួលដី និងផ្ទះជំនួសកូនរហូតដល់នីតិភាព)

១.១.៤/ ចំពោះប្រាក់ប្រដាប់ក្តីលើកម្មវត្ថុផ្សេងៗ ដើមចោទជាអ្នកទទួលបន្ទុក ។

១.២/ ការពន្យល់ត្រួសៗអំពីរឿងក្តី៖

ដើមចោទឈ្មោះ [redacted]គីមហៀក និងចុងចម្លើយឈ្មោះ [redacted] រ៉ាំត បានរៀបអាពាហ៍ពិពាហ៍តាមប្រពៃណីខ្មែរ និង បានចុះសំបុត្រ អាពាហ៍ពិពាហ៍នៅសង្កាត់ព្រែកកក់ ខេត្តកំពង់ចាម ។ នៅក្នុងអំឡុងរស់នៅជាមួយគ្នាជាប្តីប្រពន្ធ ដើមចោទ និងចុងចម្លើយឈ្មោះ [redacted] រ៉ាំត បានបង្កើតកូនចំនួន០៣នាក់ ទី១.ឈ្មោះ [redacted] សុខណៃ ភេទស្រី កើតថ្ងៃទី៣០ ខែមករា ឆ្នាំ ២០១០,ទី២.ឈ្មោះ [redacted]សុខណា ភេទស្រី កើតថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០១៣ និងទី៣.ឈ្មោះ [redacted] មន្នីរាជ ភេទប្រុស កើតថ្ងៃទី០៤ ខែកញ្ញា ឆ្នាំ២០២០ ។ ចំពោះ ទ្រព្យសម្បត្តិរួម ដើមចោទ និងចុងចម្លើយឈ្មោះ [redacted] រ៉ាំត មានដីមានចំនួន០១កន្លែង ទំហំ ៣២ម៉ែត្រ គុណនឹង ១២០ ម៉ែត្រ និងផ្ទះឈើ ទំហំ១០ម៉ែត្រ គុណនឹង២០ម៉ែត្រ មានទីតាំងស្ថិតនៅភូមិត្រាំចាន ឃុំព្រះ ប្រឡាយ ស្រុក ត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ ។ លុះដល់ឆ្នាំ២០២២ ដើមចោទ និងចុងចម្លើយឈ្មោះ [redacted]រ៉ាំត រស់ នៅមិនដែលមានសុភមង្គល និងក្តីសុខ ជាមួយគ្នាម្តងណាឡើយ ។ មិនត្រឹមតែប៉ុណ្ណោះឈ្មោះ [redacted] រ៉ាំត ធ្លាប់គំរាមកំហែង ថានឹងសម្លាប់ដើមចោទ នៅថ្ងៃណាមួយ ទង្វើនេះធ្វើឱ្យប៉ះពាល់ដល់ផ្លូវចិត្ត សន្តិអារម្មណ៍ និងដើមចោទមានការភ័យខ្លាច បាត់បង់ ជីវិតនៅថ្ងៃណាមួយមិនខាន ហេតុនេះទើបដើមចោទមកដាក់ពាក្យបណ្តឹងនៅតុលាការតែម្តង ។

១-៣/ សេចក្តីថ្លែងការណ៍របស់គូភាគី៖

ក-សេចក្តីថ្លែងការណ៍របស់ដើមចោទ៖

មេធាវីតំណាងឲ្យដើមចោទឈ្មោះ [redacted] គីមហៀក បានថ្លែងការណ៍ថា៖ ខ្លួនជាមេធាវីតំណាងឲ្យដើមចោទឈ្មោះ [redacted] គីមហៀក ភេទស្រី គឺខ្លួនសូមរក្សាទាមទារក្នុងកំណត់ហេតុស្តីពីនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ចុះថ្ងៃទី០៦ ខែតុលា ឆ្នាំ២០២៣ នៅដដែល ដោយមិនមានការកែប្រែឡើយ ។ ដើមចោទ និងចុងចម្លើយឈ្មោះ [redacted] រ៉ាំត បានរៀប អាពាហ៍ពិពាហ៍តាមប្រពៃណីខ្មែរ និងបានចុះសំបុត្រ អាពាហ៍ពិពាហ៍នៅសង្កាត់ព្រែកកក់ ខេត្តកំពង់ចាម ។ នៅក្នុងអំឡុង រស់នៅជាមួយគ្នាជាប្តីប្រពន្ធ ដើមចោទ និងចុងចម្លើយឈ្មោះ [redacted] រ៉ាំត បានបង្កើតកូនចំនួន០៣នាក់ ទី១.ឈ្មោះ [redacted]សុខណៃ ភេទស្រី កើតថ្ងៃទី៣០ ខែមករា ឆ្នាំ ២០១០,ទី២.ឈ្មោះ [redacted]សុខណា ភេទស្រី កើតថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០១៣ និងទី៣.ឈ្មោះ [redacted]មន្នីរាជ ភេទប្រុស កើតថ្ងៃទី០៤ ខែកញ្ញា ឆ្នាំ២០២០ ។ ចំពោះ ទ្រព្យសម្បត្តិរួម ដើមចោទ និងចុងចម្លើយឈ្មោះ [redacted] រ៉ាំត មានដីមានចំនួន០១កន្លែង ទំហំ៣២ម៉ែត្រ គុណនឹង ១២០ ម៉ែត្រ និងផ្ទះឈើ ទំហំ១០ម៉ែត្រ គុណនឹង២០ម៉ែត្រ មានទីតាំង ស្ថិតនៅភូមិត្រាំចាន ឃុំព្រះប្រឡាយ ស្រុក ត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ ។ លុះដល់ឆ្នាំ២០២២ ដើមចោទ និងចុង ចម្លើយឈ្មោះ [redacted] រ៉ាំត រស់នៅមិនដែលមានសុភមង្គល និងក្តីសុខ ជាមួយគ្នាម្តងណាឡើយ ។ មិនត្រឹមតែប៉ុណ្ណោះឈ្មោះ



Scanned with CamScanner

[redacted] រ៉ាត ធ្លាប់គំរាមកំហែងថានឹងសម្លាប់ដើមចោទ នៅថ្ងៃណាមួយ ទង្វើនេះធ្វើឱ្យប៉ះពាល់ដល់ផ្លូវចិត្ត សន្តិអារម្មណ៍ និងដើមចោទមានការភ័យខ្លាចបាត់បង់ ជីវិតនៅថ្ងៃណាមួយមិនខាន ហេតុនេះទើបដើមចោទមកដាក់ពាក្យបណ្តឹងនៅតុលាការ ដើម្បីឱ្យតុលាការចេញសាលក្រមសម្រេច ដូចការទាមទារខាងលើ ។

ខ-សេចក្តីថ្លែងការណ៍របស់ចុងចម្លើយ៖

ចុងចម្លើយឈ្មោះ [redacted] រ៉ាត បានថ្លែងការណ៍ថា៖ ខ្លួននៅតែរក្សាសេចក្តីថ្លែងការណ៍ក្នុងកំណត់ហេតុស្តីពីនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ចុះថ្ងៃទី០៦ ខែតុលា ឆ្នាំ២០២៣ នៅដដែល ដោយមិនមានការកែប្រែឡើយ ។ ខ្លួនពិតជាបានរៀបអាពាហ៍ពិពាហ៍ជាមួយដើមចោទឈ្មោះ [redacted] គីមហៀក ជាប្តីប្រពន្ធពិតប្រាកដមែន ដោយមានសំបុត្រអាពាហ៍ពិពាហ៍លេខ: ៣៤ ចុះថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០០៩ ផងដែរ ។ ពេលនេះខ្លួន ឯកភាពព្រមលែងលះជាមួយចុងចម្លើយឈ្មោះ [redacted] គីមហៀក ភេទស្រី ចាប់ពីពេលនេះតទៅ ។ ខ្លួនក៏យល់ព្រមប្រគល់សិទ្ធិគ្រប់គ្រងលើកូនទាំងបីនាក់ ១. ឈ្មោះ [redacted] សុខណៃ ភេទស្រី កើតថ្ងៃទី៣០ ខែមករា ឆ្នាំ២០១០, ២.ឈ្មោះ [redacted] សុខណា ភេទស្រី កើតថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០១៣ និង ៣.ឈ្មោះ [redacted] មន្នីរាជ ភេទប្រុស កើតថ្ងៃទី០៤ ខែកញ្ញា ឆ្នាំ២០២០ ឱ្យទៅដើមចោទឈ្មោះ [redacted] គីមហៀក ភេទស្រី ជាអ្នកគ្រប់គ្រងចិញ្ចឹមបីបាច់ថែរក្សា និងជាអ្នកបង់អាហារកិច្ចចិញ្ចឹមកូនទាំងបីនាក់នេះ រហូតដល់នីតិភាពផងដែរ ។ ចំពោះទ្រព្យសម្បត្តិរួម មានដីចំនួន០១កន្លែង មានទំហំ៣២ម៉ែត្រ គុណនឹង ១២០ម៉ែត្រ និងផ្ទះឈើទំហំ១០ម៉ែត្រ គុណនឹង២០ម៉ែត្រ ទីតាំងស្ថិតនៅភូមិត្រាំចាន ឃុំព្រះប្រឡាយ ស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ ខ្លួនសុខចិត្តប្រគល់ឱ្យកូនបង្កើតទាំងបីនាក់ខាងលើ ទទួលបានចំណែកស្មើៗគ្នា ដោយឱ្យដើមចោទឈ្មោះ [redacted] គីមហៀក ជាអ្នកតំណាងទទួលជំនួសបណ្តោះអាសន្នសិន ទុកឱ្យកូនទាំង០៣នាក់ដល់នីតិភាព ។ ចំពោះប្រាក់ប្រដាប់ក្តីផ្សេងៗ ខ្លួនឯកភាពព្រមឱ្យដើមចោទជាអ្នកទទួលបន្ទុក ។

- <u>ចំណុចវិវាទ៖ គ្មាន ។</u>

១-៤/ ភស្តុតាងជាឯកសារមានដូចជា៖

-សំបុត្រអាពាហ៍ពិពាហ៍លេខ: ៣៤ ចុះថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០០៩ ។

-ពាក្យស្នើសុំកាន់កាប់ប្រើប្រាស់ដីធ្លីលេខ: ២១៧/១៣ ចុះថ្ងៃទី០៥ ខែកក្កដា ឆ្នាំ២០១៣ ។

-ពាក្យស្នើសុំបញ្ជាក់ប្រវត្តិនៃការកាន់កាប់ប្រើប្រាស់ដីធ្លីលេខ: ៤៧២/២០ ចុះថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០១៣ ។

-ក្រោយពីបានឆ្លងកាត់នីតិវិធីទាញហេតុផលដោយផ្ទាល់មាត់

-ក្រោយពីបានស្តាប់សេចក្តីថ្លែងការរបស់គូភាគី

-ក្រោយពីបានពិនិត្យភស្តុងតាង នាពេលទាញហេតុផលដោយផ្ទាល់មាត់

-ក្រោយពីបានពិនិត្យ និងពិចារណាត្រឹមត្រូវតាមច្បាប់រួចហើយ ។

## <u>២-សំអាងហេតុ</u>

២.១/ ទទួលស្គាល់ពាក្យបណ្តឹងរបស់ដើមចោទឈ្មោះ [redacted] គីមហៀក ភេទស្រី កើតឆ្នាំ១៩៨៩ សញ្ជាតិខ្មែរ ដោយមានលោក [redacted] ជាមេធាវីតំណាងដោយអាណត្តិ ចុះថ្ងៃទី០៤ ខែតុលា ឆ្នាំ២០២៣ ធ្វើឡើងមានលក្ខណៈត្រឹមត្រូវតាមទម្រង់ និង គតិច្បាប់ ។



Scanned with CamScanner

២.២/ ការរួមរស់នៅជាមួយគ្នារបស់អ្នកទាំងពីរគឺមានកូនចំនួន ០៣នាក់ មាន៖

ក.ឈ្មោះ [redacted] សុខណៃ ភេទស្រី កើតថ្ងៃទី៣០ ខែមករា ឆ្នាំ២០១០ ។

ខ.ឈ្មោះ [redacted] សុខណា ភេទស្រី កើតថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០១៣ ។

គ.ឈ្មោះ [redacted] មន្នីរាជ ភេទប្រុស កើតថ្ងៃទី០៤ ខែកញ្ញា ឆ្នាំ២០២០ ។

២.៣/ ការរួមរស់នៅជាមួយគ្នារបស់អ្នកទាំងពីរគឺមានទ្រព្យសម្បត្តិរួមមានដូចជា៖

ក.ដីចំនួន០១កន្លែង មានទំហំ៣២ម៉ែត្រ គុណនឹង ១២០ម៉ែត្រ និងផ្ទះឈើទំហំ១០ម៉ែត្រ គុណនឹង២០ម៉ែត្រ មានទីតាំងស្ថិតនៅភូមិត្រាំចាន ឃុំព្រះប្រឡាយ ស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ ។

២.៤/ ផ្អែកតាមសេចក្ដីថ្លែងការណ៍របស់គូភាគីក្នុងនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ ឃើញថា: ដើមចោទ និង ចុងចម្លើយ បានឯកភាពព្រមលែងលះគ្នាចាប់ពីពេលនេះតទៅ ។ យោងតាមមាត្រា ៩៧៩ នៃក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ភាគីនៃអាហ៍ពិពាហ៍ អាចដាក់ពាក្យបណ្ដឹងលែងលះ ទៅតុលាការបាន ក្នុងករណីដែលភាគីសងខាងបានព្រមព្រៀងអំពីការលែងលះគ្នា ដូច្នេះគប្បីតុលាការពិនិត្យ និងសម្រេចតាមការព្រមព្រៀងរបស់គូភាគី ។

២.៥/ ផ្អែកតាមសេចក្ដីថ្លែងការណ៍របស់គូភាគីក្នុងនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ ឃើញថា: ដើមចោទ និង ចុងចម្លើយ បានព្រមព្រៀងប្រគល់សិទ្ធិគ្រប់គ្រងលើកូនចំនួន០៣នាក់ មានឈ្មោះ [redacted] សុខណៃ ភេទស្រី កើតថ្ងៃទី៣០ ខែមករា ឆ្នាំ២០១០, ឈ្មោះ [redacted] សុខណា ភេទស្រី កើតថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០១៣ និងឈ្មោះ [redacted] មន្នីរាជ ភេទប្រុស កើតថ្ងៃទី ០៤ ខែកញ្ញា ឆ្នាំ២០២០ ឲ្យទៅដើមចោទជាអ្នកទទួលបន្ទុកគ្រប់គ្រង និងចិញ្ចឹមបីបាច់ថែរក្សារហូតដល់នីតិភាព ។ យោងតាមមាត្រា ១០៣៧ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា បើឪពុកម្ដាយលែងលះគ្នា ត្រូវកំណត់យកឪពុក ឬម្ដាយណាម្ខាង ជាអ្នកមានអំណាចមេបា តាមការពិភាក្សារបស់ឪពុកម្ដាយ ដូច្នេះគប្បីតុលាការពិនិត្យ និងសម្រេចតាមការព្រមព្រៀងរបស់គូភាគី ។

២.៦/ ផ្អែកតាមសេចក្ដីថ្លែងការណ៍របស់គូភាគីក្នុងនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ ឃើញថា: ដើមចោទ និង ចុងចម្លើយបានឯកភាពព្រមព្រៀងគ្នា ប្រគល់ទ្រព្យសម្បត្តិរួមមាន ដីចំនួន០១កន្លែង មានទំហំ៣២ម៉ែត្រ គុណនឹង ១២០ ម៉ែត្រ និងផ្ទះឈើទំហំ១០ម៉ែត្រ គុណនឹង២០ម៉ែត្រ ទីតាំងស្ថិតនៅភូមិត្រាំចាន ឃុំព្រះប្រឡាយ ស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ ឲ្យកូនបង្កើតទាំង០៣នាក់ មានឈ្មោះ [redacted] សុខណៃ ភេទស្រី កើតថ្ងៃទី៣០ ខែមករា ឆ្នាំ២០១០, ឈ្មោះ [redacted] សុខណា ភេទស្រី កើតថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០១៣ និងឈ្មោះ [redacted] មន្នីរាជ ភេទប្រុស កើតថ្ងៃទី០៤ ខែកញ្ញា ឆ្នាំ២០២០ ទទួលបានចំណែកស្មើៗគ្នា ដោយឲ្យដើមចោទឈ្មោះ [redacted] គីមហៀក ជាអ្នកតំណាងទទួលជំនួសបណ្ដោះអាសន្នសិន ទុកឲ្យកូនទាំង ០៣នាក់ដល់នីតិភាព ។ យោងតាមមាត្រា ៩៨០ កថាខណ្ឌ១ នៃក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ក្នុងករណីដែលប្ដីប្រពន្ធលែងលះគ្នា ត្រូវបែងចែកទ្រព្យសម្បត្តិដោយយុត្តិធម៌ ផ្អែកតាមការពិភាក្សារបស់ភាគីទាំងសងខាង ដូច្នេះគប្បីតុលាការពិនិត្យ និងសម្រេចតាមការព្រមព្រៀងរបស់គូភាគី ។

២.៧/ ផ្អែកតាមសេចក្ដីថ្លែងការណ៍របស់គូភាគីក្នុងនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ ឃើញថា: ដើមចោទ និង ចុងចម្លើយបានឯកភាពព្រមព្រៀងគ្នា ឲ្យដើមចោទជាអ្នកទទួលបន្ទុកប្រាក់ប្រដាប់ក្ដី ។ យោងតាមមាត្រា ៦៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី ដូច្នេះគប្បីតុលាការពិនិត្យ និងសម្រេចតាមការព្រមព្រៀងរបស់គូភាគី ។



Scanned with CamScanner

## ៣-សេចក្តីសម្រេចបញ្ចប់

១/ ទទួលស្គាល់ពាក្យបណ្តឹងរបស់ដើមចោទឈ្មោះ [redacted] គឹមហៀក ភេទស្រី កើតឆ្នាំ១៩៨៩ សញ្ជាតិខ្មែរ ដោយមាន លោក [redacted] ជាមេធាវីតំណាងដោយអាណត្តិ ចុះថ្ងៃទី០៤ ខែតុលា ឆ្នាំ២០២៣ ធ្វើឡើងមានលក្ខណៈត្រឹមត្រូវ តាមទម្រង់ និង គតិច្បាប់ ។

២/ រំលាយចំណងអាពាហ៍ពិពាហ៍រវាងដើមចោទឈ្មោះ [redacted] គឹមហៀក និងចុងចម្លើយឈ្មោះ [redacted] រ៉ាត ។

៣/ ប្រគល់សិទ្ធិគ្រប់គ្រងកូនចំនួន០៣នាក់ មានឈ្មោះ [redacted] សុខណៃ ភេទស្រី កើតថ្ងៃទី៣០ ខែមករា ឆ្នាំ២០១០, ឈ្មោះ [redacted] សុខណា ភេទស្រី កើតថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០១៣ និងឈ្មោះ [redacted] មន្នីរាជ ភេទប្រុស កើតថ្ងៃទី០៤ ខែកញ្ញា ឆ្នាំ ២០២០ ឱ្យទៅដើមចោទជាអ្នកទទួលបន្ទុកគ្រប់គ្រង និងចិញ្ចឹមបីបាច់ថែរក្សា ទុកសិទ្ធិឱ្យចុងចម្លើយ អាចទៅសួរសុខទុក្ខ កូនទៅវិញទៅមកបាន រៀងរាល់ថ្ងៃសៅរ៍ និងថ្ងៃអាទិត្យ ដើម្បីកុំឱ្យប៉ះពាល់ម៉ោងសិក្សារបស់កូន ។ មាតាបិតាត្រូវមាន សិទ្ធិ និងករណីកិច្ចអប់រំចិញ្ចឹមបីបាច់ថែរក្សាកូនឱ្យបានល្អតាមបញ្ញត្តិច្បាប់ ។

៤/ ប្រគល់សិទ្ធិគ្រប់គ្រងលើទ្រព្យសម្បត្តិរួមមាន ដីចំនួន០១កន្លែង មានទំហំ៣២ម៉ែត្រ គុណនឹង ១២០ម៉ែត្រ និងផ្ទះឈើទំហំ១០ម៉ែត្រ គុណនឹង២០ម៉ែត្រ ទីតាំងស្ថិតនៅភូមិត្រាំចាន ឃុំព្រះប្រឡាយ ស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ ឱ្យកូនបង្កើតទាំង០៣នាក់ មានឈ្មោះ [redacted] សុខណៃ ភេទស្រី កើតថ្ងៃទី៣០ ខែមករា ឆ្នាំ២០១០, ឈ្មោះ [redacted] សុខណា ភេទស្រី កើតថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០១៣ និងឈ្មោះ [redacted] មន្នីរាជ ភេទប្រុស កើតថ្ងៃទី០៤ ខែកញ្ញា ឆ្នាំ២០២០ ទទួលបានចំណែកស្មើៗគ្នា ដោយឱ្យដើមចោទឈ្មោះ [redacted] គឹមហៀក ជាអ្នកតំណាងទទួលជំនួសបណ្តោះអាសន្នសិន រហូតដល់កូន០៣នាក់ខាងលើ ក្លាយជានីតិជន ។

៥/ ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ដើមចោទ ។

សាលក្រមនេះធ្វើការទាញហេតុផលដោយផ្ទាល់មាត់នៅថ្ងៃ ចន្ទ ៨រោច ខែអស្សុជ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧ ត្រូវនឹងថ្ងៃទី០៦ ខែវិច្ឆិកា ឆ្នាំ២០២៣ និងប្រកាសជាសាធារណៈនៅថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០២៣ ចំពោះមុខគូភាគី ។

-ទុកសិទ្ធិឱ្យប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់ ។

ថ្ងៃ ពុធ ៣កើត ខែកត្តិក ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

ខេត្តឧត្តរមានជ័យ ថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០២៣

**ចៅក្រម**

**ហត្ថលេខា និងត្រា៖** [redacted]

---

**បានចម្លងត្រឹមត្រូវតាមច្បាប់ដើម**

ថ្ងៃ ពុធ ៣កើត ខែកត្តិក ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

ខេត្តឧត្តរមានជ័យ ថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០២៣

**ក្រឡាបញ្ជី**

S-VISAL

[redacted]

**បានឃើញ**

**ចៅក្រម**

[redacted]



Scanned with CamScanner